# សេចក្តីប្រកាសព័ត៌មានស្តីពី
# ការប្រារព្ធទិវាបរិស្ថានពិភពលោកឆ្នាំ២០២៥

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២៥

សមាគម អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងក្រុមយុវជនចំនួន៧ស្ថាប័ន នឹងប្រារព្ធទិវាបរិស្ថានពិភពលោកខួបលើកទី២៩ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៥ ក្រោមមូលបទស្តីពី **«គោលនយោបាយល្អ ការអនុវត្តត្រឹមត្រូវ កម្ពុជាស្អាត» នៅភោជនីយដ្ឋានទន្លេរបាសាក់២ រាជធានីភ្នំពេញ ចាប់ពីវេលាម៉ោង១ រសៀល ដល់ម៉ោង ៥ ល្ងាច។** ការរៀបចំទិវានេះធ្វើឡើងក្នុងគោលបំណងសំខាន់ៗចំនួន៤ ៖ ១) ដើម្បីអបរសាទរទិវាបរិស្ថានពិភពលោកឆ្នាំ២០២៥ នៅប្រទេសកម្ពុជា, ២) ជំរុញការអនុវត្តគោលនយោបាយជាតិ អន្តរជាតិព្រមទាំងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធអំពីបញ្ហាបរិស្ថាន និងបម្រែបម្រួលអាកាសធាតុ, ៣) លើកកម្ពស់ការចូលរួមពីសាធារណជនក្នុងការតាមដានការអនុវត្តគោលនយោបាយដើម្បីរក្សាបរិស្ថានស្អាត និងការការពារធនធានធម្មជាតិ ជាពិសេសក្រើនរំលឹកពីផលប៉ះពាល់ដោយសារការប្រើប្រាស់ប្លាស្ទិក និងការបំពុលខ្យល់, និង ៤) ប្រមូលធាតុចូលពីប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន យុវជន ជាពិសេសសជនងាយរងគ្រោះដើម្បីដាក់បញ្ចូលក្នុងសេចក្តីថ្លែងការណ៍រួមអំពីបញ្ហាប្រឈម សំណូមពរដំណោះស្រាយពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយបរិស្ថាន និងធនធានធម្មជាតិ។

ក្នុងអំឡុងពេលប្រារព្ធទិវាបរិស្ថានពិភពលោកនៅឆ្នាំនេះ យើងខ្ញុំនឹងមានការរៀបចំសកម្មភាពរួមមាន៖ ១) ការសម្តែងល្ខោនជីវិតឆ្លុះបញ្ចាំងអំពីផលប៉ះពាល់ដោយសារបំពុលបរិស្ថាន, ២) កិច្ចពិភាក្សាតុមូលស្តីពីកំណើននៃការបំពុលបរិស្ថាន និងដំណោះស្រាយ, ៣) កិច្ចពិភាក្សាក្រុមតូចឆ្លុះបញ្ចាំងពីទស្សនយុវជន សហគមន៍មូលដ្ឋានជុំវិញបរិស្ថាន, ៤) តាំងពិព័រណ៍កូនឈើ និងឆ្លើយសំណួរយករង្វាន់, និង ៥) ចម្រៀងយុវជនបរិស្ថាន។

ប្រសិនបើលោកអ្នកមានចំណាប់អារម្មណ៍ចង់ចូលរួមយុទ្ធនាការដើម្បីអបអរសាទរទិវាបរិស្ថានឆ្នាំ២០២៥ នេះ លោកអ្នកគ្រាន់តែបង្ហោះសាររបស់ខ្លួន និងរូបភាពបង្ហាញពីការចូលរួមការពារសិទ្ធិបរិស្ថាន ការទប់ស្កាត់ បម្រែបម្រួលអាកាសធាតុ ការចូលរួមការពារធនធានធម្មជាតិ និងព្រៃឈើដែលភ្ជាប់ជាមួយពាក្យមួយឃ្លាថា **«គោលនយោបាយល្អ ការអនុវត្តត្រឹមត្រូវ កម្ពុជាស្អាត»** ជាការស្រេច។

អាស្រ័យដូចមានក្នុងសេចក្តីប្រកាសព័ត៌មានខាងលើនេះ សូមអង្វាធរ អ្នកសារព័ត៌មាន និងសាធារណជនអញ្ជើញចូលរួម និងជ្រាបជាព័ត៌មាន។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖


១. លោក សាន់ ម៉ាឡា អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ ទូរសព្ទលេខ ០១៥ ៩៩៨ ៥៥៥

២. លោក វណ្ណៈ ប៊ុនណា សមាគមបណ្តាញយុវជនកម្ពុជា ទូរសព្ទលេខ ០៨៥ ៨២៨ ២៧៧

៣. លោក វណ្ណៈ សុផាត មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ទូរសព្ទលេខ ០១២ ៩៤១ ២០៦